00891407

E264/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 03 / 2013
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីនៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធាន អង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង មន្ត្រីសម្របសម្រួលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ៖** ការពន្យារពេលស្ដាប់សក្ខីកម្មអ្នកជំនាញ

1. នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានទទួលការជូនដំណឹងថា ជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយមិនមានការបញ្ជាក់ថាតើនៅពេលណាដែលគាត់នឹងត្រឡប់មកមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក វិញឡើយ។ នៅថ្ងៃដដែលនេះ អង្គជំនុំជម្រះក៏បានទទួលការជូនដំណឹងដែរថា បុគ្គលិកជាតិនៅអង្គភាពផ្នែកបកប្រែភាសារបស់ អ.វ.ត.ក នឹងមិនផ្ដល់ការបកប្រែភាសានោះទេ រហូតទាល់តែពួកគេបានទទួលប្រាក់បៀវត្សសម្រាប់ខែ ធ្នូ ឆ្នាំ ២០១២ និង ខែ មករា ខែ កុម្ភៈ ឆ្នាំ ២០១៣ (ឯកសារ E1/174.1)។ ហេតុដូច្នេះ អង្គជំនុំជម្រះ មិនអាចធ្វើសវនាការស្ដាប់សក្ខីកម្មអ្នកជំនាញ Philip SHORT និង Elizabeth BECKER បានឡើយ។ អាស្រ័យហេតុនេះ ការផ្ដល់សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូបត្រូវពន្យារពេល ហើយការជូនដំណឹងបន្ថែមទាក់ទងនឹងការកំណត់កាលបរិច្ឆេទថ្មីសម្រាប់ការធ្វើសក្ខីកម្មរបស់អ្នកជំនាញទាំងពីររូបនេះនឹងផ្ដល់ជូនក្នុងពេលសមស្រប។

2. អាស្រ័យដូចបានបញ្ជាក់ខាងលើនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថាមិនធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីបន្ថែមទៀតឡើយ នៅមុនពេលមានសេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E264/1)។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី គឺជាប់ពាក់ព័ន្ធនឹងភស្តុតាងដែលផ្តល់ដោយអ្នកជំនាញវេជ្ជសាស្ត្រដែលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទក្នុងការស្តាប់សក្ខីកម្មនៅក្នុងអំឡុងសប្តាហ៍ដែលចាប់ផ្តើមពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣។ វិធានការណ៍ផ្សេងៗដើម្បីពន្លឿនការវាយតម្លៃអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទឱ្យបានមុនកាលបរិច្ឆេទនេះ ត្រូវបានស្វះស្វែងរួចហើយ ប៉ុន្តែមិនអាចអនុវត្តបានទេដោយសារតែអ្នកជំនាញមិនមានពេលវេលាគ្រប់គ្រាន់។

3. បន្ទាប់ពីអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងបន្ទាប់ពីបានស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាក់ទងនឹងសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ អៀង សារី និង នួន ជា នោះ អង្គជំនុំជម្រះនឹងជូនដំណឹងបន្ថែមទៀតដល់ភាគីទាំងអស់ទាក់ទងនឹងការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការ។